# របាយការណ៍សង្ខេប
# បូកសរុបលទ្ធផលការងារ អាណត្តិទី ៥
# (ឆ្នាំ២០១០ - ឆ្នាំ២០១៤)
# និង ទិសដៅការងារ អាណត្តិទី ៦
# មហាសន្និបាត កាកបាទក្រហមកម្ពុជា អាណត្តិទី ៦
# ថ្ងៃទី ៦-៧ ខែសីហា ឆ្នាំ២០១៤ នាសាលសន្និសីទចតុម្មុខ
# សរុបដោយ លោកជំទាវអគ្គលេខាធិការ

សូមគោរព ៖

- **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានអង្គមហាសន្និបាត ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- គណៈអធិបតី  អង្គមហាសន្និបាត អាណត្តិទី៦ ជាទីគោរព !
- សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ សមាជិក សមាជិកា នៃអង្គមហាសន្និបាត ជាទីគោរព !

រយៈពេល៤ឆ្នាំចុងក្រោយនេះ ជារយៈពេលដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងបន្តទទួលផលយ៉ាងពេញលេញពីសុខសន្តិភាព ស្ថេរភាពនយោបាយ សេដ្ឋកិច្ច និងការអភិវឌ្ឍ ក៏ប៉ុន្តែ ជាមួយនោះ ក៏បានទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ វិបត្តិហិរញ្ញវត្ថុ ការធ្លាក់ចុះនៃ

សេដ្ឋកិច្ចពិភពលោក ការរីករាលដាលនៃជំងឺឆ្លង ដែលបង្កហានិភ័យយ៉ាងធ្ងន់ធ្ងរដល់មនុស្សជាតិទាំងមូល។

អាណត្តិទី៥នេះ ស្ថិតក្នុងរយៈពេល៤ឆ្នាំដំបូង នៃការអនុវត្តយុទ្ធសាស្ត្រ ២០១១-២០២០ ដែលបានអនុម័តជាឯកច្ឆ័ន្ទនៅមហាសន្និបាតកាកបាទក្រហមកម្ពុជា (កក្រក) អាណត្តិទី ៥។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមលើកឡើងពីប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ថ្លែងក្នុងខួបទី ១៤៧ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ឆ្នាំ ២០១០ ថា "**ខ្ញុំជឿជាក់ថា អំណិះតទៅ កក្រក នៅតែជាស្ថាប័ន មនុស្សធម៌ដ៏ធំមួយនៅកម្ពុជា ដែលត្រូវបន្តដើរតួនាទីជាសេនាធិការដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងជាដៃគូដ៏សកម្ម ចំពោះគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងវិស័យមនុស្សធម៌ ដើម្បីជួយដោះស្រាយ និងសម្រាលទុក្ខលំបាកផងទាំងពួងរបស់ប្រជាជនកម្ពុជាដែលទទួលរងគ្រោះ។** យោងតាមប្រសាសន៍ ដ៏មានខ្លឹមសារ និងក្រើនរំលឹក ដ៏វិសេសវិសាលនេះ រយៈពេល៤ឆ្នាំនៃអាណត្តិទី៥ កក្រក ក្រោមការដឹកនាំ ការណែនាំ និងតម្រង់ទិសរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ប្រកបដោយប្រាជ្ញាឈ្លាសវៃ ម៉ឺងម៉ាត់ ហ្មត់ចត់ មានតម្លាភាព និងគណនេយ្យភាព ក្នុងភាពជាអ្នកដឹកនាំ បានដាក់ទិសវិមជ្ឈការ និងវិសហមជ្ឈការ ទាំងថ្នាក់កណ្តាល សាខា អនុសាខា និងមូលដ្ឋាន ទើបសម្រេចបាននូវសមិទ្ធផលធំៗ គួរឲ្យមោទនៈ ដូចខាងក្រោមនេះ ៖

## I-**ទិសយុទ្ធសាស្ត្រទី១**: **រួមចំណែកសង្គ្រោះជីវិត កសាងភាពធន់ទ្រាំនៅនឹងគ្រោះមហន្តរាយ និង វិបត្តិផ្សេងៗ (វិស័យស្នូលទី១ : ការគ្រប់គ្រងគ្រោះមហន្តរាយ )**

## សកម្មភាពទី១: ការផ្តល់អំណោយមនុស្សធម៌

ការត្រៀមបង្ការ និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ មិនប្រាកដថា អាចបញ្ចៀសផលប៉ះពាល់ ទាំងស្រុងបាននោះទេ ហេតុនេះហើយទើប **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា បានចង្អុលបង្ហាញទិសយុទ្ធសាស្ត្រគន្លឹះ ឲ្យរួមចំណែកក្នុងការដោះស្រាយ ផលវិបាកនានាដែលបង្កឡើង ដោយការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមជាច្រើន ដោយបាន ឧបត្ថម្ភស្បៀង សម្ភារៈ ដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ មានដូចជាខ្យល់ព្យុះ ខ្យល់កន្ត្រាក់ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ គ្រោះអគ្គិភ័យ គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះមហន្តរាយ ដោយប្រការផ្សេងៗ សរុបរួមចំនួន **៦២៥,៧០៣ គ្រួសារ** ដោយផ្តោតលើចាស់ជរាគ្មានទីពឹង ស្ត្រីមេម៉ាយ កុមារកំព្រា ជនពិការ កុមារគ-ថ្លង់ យុវជនញៀនថ្នាំ និងអ្នករស់នៅជាមួយមេរោគអេដស៍ ជំងឺអេដស៍ បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព សមស្រប នឹងទិសស្លោក " ***ទីណាមានទុក្ខលំបាក ទីនោះមានកាកបាទក្រហមកម្ពុជា*** "។

ក្នុងកញ្ចប់ការងារ នេះ កក្រក បានផ្តល់ ៖

១) ម៉ាស៊ីនបូមទឹក (ជំនួយរបស់ កក្រ ចិន) ចំនួន ១៤៦គ្រឿង ជូនសាខាទាំង២៤

២) សាងសង់ផ្ទះ ២០ខ្នង និងជួសជុលផ្ទះចំនួន ៤១ខ្នង ជូនប្រជាពលរដ្ឋទីទ័លក្រគ្មានជម្រក ក្នុងខេត្តគោលដៅចំនួន៤ និងប្រជាពលរដ្ឋរងគ្រោះដោយជម្លោះប្រដាប់អាវុធ នៅខេត្តឧត្តរមានជ័យ

៣) សហការជាមួយមន្ទីរពេទ្យចំនួន៤ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជួយឆ្លើយតបឧបទ្ទវហេតុ ស្ពានពេជ្រដោយបានស្រាវជ្រាវ ចុះឈ្មោះអ្នកបាត់ខ្លួន អ្នករបួស កំណត់អត្តសញ្ញាណសព និងបំពេញបែបបទប្រគល់សពជូនក្រុមគ្រួសារ សរុបចំនួន ៣៣៧នាក់

និងផ្តល់កញ្ចប់អំណោយ ជូនអ្នករបួសសម្រាកមន្ទីរពេទ្យ និង គ្រួសារសពចំនួន ៣៥៥ គ្រួសារ។

ដោយឡែក តាមរយៈមរតកសាសន៍លោក ហ្គីហាត មោតាលិក ជនជាតិអូទ្រីស ដើម្បីមរតកនេះ នៅស្ថិតស្ថេរ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** បានផ្តួចផ្តើមគំនិតកសាងអគារសិក្សា ៣ខ្នង (២ខ្នង នៅ ខេត្តកណ្តាល និង ១ខ្នងទៀត នៅខេត្តកំពង់ចាម ដែលអគារនីមួយៗ មានកំពស់ ២ជាន់ មាន ៣០បន្ទប់។

តាមរយៈសកម្មភាពគម្រោងទទួលថវិកាពីដៃគូ បានផ្តល់ជូនប្រជាពលរដ្ឋងាយរងគ្រោះ នៅសហគមន៍មូលដ្ឋាន រួមមាន ៖

- ផ្តល់ផ្ទះចំនួន ២១១ខ្នង និងគ្រោងផ្ទះ ១៤០ ខ្នង
- អង្ករ ១,៤៨៥តោន
- ស្រះទឹកសហគមន៍ ២ កន្លែង បង្គន់អនាម័យ ១៤០ កន្លែង
- ទូកចំនួន ៣៧៥ គ្រឿង
- ធុងចម្រោះខ្យាច់បំពាក់ដោយថាមពលពន្លឺព្រះអាទិត្យ ៥កន្លែង ធុងចម្រោះទឹកស្អាត ១,០៥៥ សម្រាប់ និងធុងទឹក ៦,៣០០។

**សកម្មភាពទី២: ការកសាងភាពធន់មាំទៅនឹងគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗ**

➢ **ការងារប្រាក់កម្ចីខ្នាតតូច៖** កក្រក ក្នុងនាមជាជំនួយការឲ្យអាជ្ញាធរសាធារណៈ និងដើម្បីរួមចំណែកជួយកាត់បន្ថយភាពក្រីក្រ បានដំណើរការការងារប្រាក់កម្ចីខ្នាតតូចពុំយកការប្រាក់ ជូនគ្រួសារងាយរងគ្រោះនៅសហគមន៍មូលដ្ឋាន ដោយមូលនិធិរើលម៉េត។ រយៈកាលកន្លងមកនេះបានជួយប្រជាពលរដ្ឋចំនួន ៩៥០គ្រួសារ នៅខេត្តគោលដៅចំនួន ៤ ឱ្យមាន

ជីវភាពប្រសើរជាងមុន និងកំពុងជួយដល់ គ្រួសារចំនួន ៥៦០ គ្រួសារទៀត ឱ្យមានជីវភាពសមរម្យជាងមុនផងដែរ។

- **ការលើកកម្ពស់សុវត្ថិភាពចរាចរណ៍៖** កក្រក បានបន្តផែនការលើកកម្ពស់សុវត្ថិភាពចរាចរណ៍ ដំណាក់កាលទី២ ដោយបានពង្រីកសកម្មភាពដល់១៥ខេត្ត ដែលនៅឆ្នាំ២០១០ មានតែ ៣ ខេត្តប៉ុណ្ណោះ។ ខេត្តគោលដៅទាំង ១៥នេះ គ្របដណ្តប់ ១៦ស្រុក ៣៨ឃុំ ៣០០ភូមិ និងក្លឹបយុវជនចំនួន ៨៣។

- បានបណ្តុះបណ្តាលគ្រូបង្គោលសុវត្ថិភាពចរាចរណ៍ចំនួន ១០៥នាក់ យុវជន កក្រក ២,៦៤០ នាក់ (ស្រី ១,០៣០នាក់) និងអ្នកស្ម័គ្រចិត្ត កក្រក ១,២៤០នាក់ (ស្រី៥១០នាក់) ។
- បានផ្តល់មួកសុវត្ថិភាពចំនួន ៦,៥០០ ជូនអ្នកទទួលផល នៅខេត្តគោលដៅចំនួន ១៥។
- បានធ្វើការផ្សព្វផ្សាយពីការលើកកម្ពស់សុវត្ថិភាពចរាចរណ៍យ៉ាងផុលផុស ទាំងនៅតាមគ្រឹះស្ថានសិក្សាគោលដៅ ទីសាធារណៈ និងតាមភ្លើងស្តុបសំខាន់ៗ។

## II- ទិសយុទ្ធសាស្ត្រទី២ : រួមចំណែកកាត់បន្ថយអត្រាឈឺ និងស្លាប់នៃមាតា និងកុមារ ការពារជំងឺឆ្លង និងអន្តរាគមន៍សុខភាពគ្រាអាសន្ន

**(វិស័យស្នូលទី២: សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍)**

ដើម្បីរួមចំណែកដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៤ ទី៥ និងទី៦ និងសំដៅរួមចំណែក សម្រេចបាននូវសូចនាករ ក្នុងយុទ្ធសាស្ត្រ ២០០៨-២០១៥ របស់ក្រសួងសុខាភិបាល កក្រក បានកំណត់ការងារអាទិភាពចំនួន ៣ ។

**សកម្មភាពទី១: ការងារឥស្សរជនឆ្នើមថ្នាក់ជាតិ និងលើកកម្ពស់សុខភាពមាតា កុមារ និងទារក**

- ថ្ងៃទី៨-១០ ខែមិថុនា ឆ្នាំ២០១១ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធាន** បានដឹកនាំប្រតិភូទៅ ចូលរួមកិច្ចប្រជុំជាន់ខ្ពស់អង្គការសហប្រជាជាតិជាមួយស្ត្រីទី១ មកពីបណ្ដាប្រទេសជុំវិញពិភពលោក ដើម្បីពិភាក្សា និងធ្វើការប្ដេជ្ញាចិត្ត ធានាទប់ស្កាត់ឱ្យបាននូវការឆ្លងមេរោគអេដស៍ ពីម្ដាយ ទៅកូន។ លើសពីនេះទៀត បានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ក្នុងការអប់រំផ្សព្វផ្សាយ សំដៅកាត់បន្ថយអត្រាស្លាប់របស់មាតា ទារក និងកុមារ។ ដោយការរួមចំណែក ឥតនឿយហត់ ចំពោះសុខុមាលភាពរបស់ប្រជាជន **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ត្រូវបានអង្គការសហប្រជាជាតិ ប្រគល់ជូននូវគោរម្យងារ ដ៏វិសេសវិសាលមួយទៀតជា "**ឥស្សរជន ឆ្នើមនៃផែនការសកម្មភាពរួម អគ្គលេខាធិការ អង្គការសហប្រជាជាតិ ដើម្បីសុខភាពស្ត្រី និងកុមារ**" នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១១។ ហើយថ្ងៃនោះ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា កំណត់ជា ទិវាជាតិ ដើម្បីសុខភាពមាតា ទារក និងកុមារ។
- ចាប់តាំងពីឆ្នាំ២០១២ រៀងរាល់ឆ្នាំ កក្រក បានប្រគល់ថវិកាចំនួន ១លានដុល្លារអាមេរិក ជូនមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីចូលរួមជួយសង្គ្រោះ និងព្យាបាលកុមារ និងទារក។
- ជារៀងរាល់ឆ្នាំ **សម្ដេចកិត្តព្រឹទ្ធបណ្ឌិតប្រធាន** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ។ បានផ្ញើសារគន្លឹះអប់រំសុខភាព ជូនប្រជាជនទូទាំងប្រទេស

ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ **១ ធ្នូ** ទិវាឆ្មបជាតិ **៥ ឧសភា** និងទិវាជាតិ សុខភាពមាតា កុមារ និងទារក **២១ កុម្ភៈ។**

- ដោយមូលនិធិរើលម៉េត បានផ្តល់អណ្តូងទឹកស្អាតចំនួន ៧៩៦ កន្លែង និងស្រះទឹកសហគមន៍ ចំនួន ១៧ កន្លែង។

និងដោយថវិកាដៃគូ ៦ទៀត អនុវត្តនៅ ១៤ខេត្តគោលដៅ បានផ្តល់ ៖

- អណ្តូងទឹកចំនួន ៧២៥ អណ្តូង បង្គន់អនាម័យ ចំនួន ៨,០៤៤បង្គន់ ធុងសំរាម ១៨ ដាក់តាមសាលារៀន ធើង ចម្រោះទឹកស្អាត ៣១,៧៨៣ សម្រាប់ និងអាងទឹកចំណុះ ជាង ៣,០០០លីត្រ ចំនួន ២១៧ អាង។
- ប្រព័ន្ធផ្គត់ផ្គង់ទឹក ដើរដោយថាមពលពន្លឺព្រះអាទិត្យចំនួន ២ កន្លែង និងចង្កៀងប្រើថាមពលពន្លឺព្រះអាទិត្យចំនួន ៣៩០ គ្រឿង។
- សម្ភារៈបរិក្ខាសម្រាប់មណ្ឌលសុខភាពចំនួន ១៤ មណ្ឌល កញ្ចប់អនាម័យសម្រាប់សម្រាលកូនចំនួន ៦០០ កញ្ចប់ និង បានបញ្ជូនស្ត្រីមានផ្ទៃពោះទៅសម្រាលកូននៅ មណ្ឌលសុខ ភាពចំនួន ៧០០នាក់។
- កង់ចំនួន ១,៣៣១ គ្រឿង និងឃីតសង្គ្រោះបឋមចំនួន ១,៥២១ ជូនអ្នកស្ម័គ្រចិត្ត កក្រក។
- ចូលរួមបដិភាគជួយសាងសង់អគារ អនុសាខា ស្រុកព្រែក ប្រសព្វ ខេត្តក្រចេះ។

## សកម្មភាពទី២ : ការការពារជំងឺឆ្លងក្នុងសហគមន៍

មានដៃគូចំនួន៥ បានឧបត្ថម្ភឲ្យអនុវត្តកម្មវិធីការពារជំងឺឆ្លង នៅខេត្ត ចំនួន៧ មានអ្នកទទួលផល ចំនួន១៣,៤៥៤ នាក់ ដោយបាន ៖

- ផ្តល់បង្គន់អនាម័យចំនួន ៥២ ស្បៀងសង្គ្រោះចំនួន ៩៦៤ កញ្ចប់ អណ្តូងទឹកចំនួន ៣ អណ្តូង អាងទឹកចំណុះជាង ៣,០០០លីត្រ ចំនួន៩៦ និងធុងចម្រោះទឹកស្អាតចំនួន ៩៥០ ដល់ គ្រួសារអ្នកផ្ទុកមេរោគអេដស៍។
- ផ្តល់កង់ចំនួន ២០៣គ្រឿង សម្លៀកបំពាក់សិស្សចំនួន ២,០០០ សម្រាប់ និងសម្ភារៈសិក្សា ចំនួន ១,០៤៩ កញ្ចប់ ដល់កុមារកំព្រា ដែលងាយរងគ្រោះដោយសារជំងឺអេដស៍។

## សកម្មភាពទី៣ : អន្តរាគមន៍សុខភាពគ្រាអាសន្ន

ឆ្លើយតបនឹងបញ្ហាប្រឈមសាកល កក្រក បាននិងកំពុងយកចិត្តទុកដាក់លើការផ្តល់វគ្គបណ្តុះបណ្តាល វគ្គបំប៉ន ដល់សាខា អនុសាខា ពីជំនាញសង្គ្រោះបឋម ដើម្បីបណ្តុះបណ្តាលបន្តដល់យុវជន អ្នកស្ម័គ្រចិត្ត ប្រជាពលរដ្ឋក្នុងសហគមន៍ ឲ្យយល់ដឹងពីវិធានការសង្គ្រោះបន្ទាន់ របៀបបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ដែលនៅជិតបំផុត និងផ្សព្វផ្សាយពីរបៀបទប់ស្កាត់កុំឲ្យ មានជំងឺឆ្លង និងវិធានការការពារខ្លួន។ ជាក់ស្តែងក្នុងអាណត្តិទី៥នេះ កក្រក សម្រេចការងារចម្បងៗ ដូចតទៅ៖

- អ្នកស្ម័គ្រចិត្ត ៧៣៨ នាក់ នៅខេត្តគោលដៅចំនួន១២ បានធ្វើការអប់រំ ការត្រៀមបង្ការជំងឺផ្តាសាយបក្សីប្រភេទថ្មី ដើម្បីផ្លាស់ប្តូរទម្លាប់អវិជ្ជមាន និងបញ្ចៀសនូវជំងឺឆ្លងទាំងឡាយ។
- ផ្តល់ការបណ្តុះបណ្តាលពីវិជ្ជាសង្គ្រោះបឋម ដោយមិនគិតកម្រៃ ដល់មន្ត្រីរាជការ យុវជន និង អ្នកស្ម័គ្រចិត្ត កក្រក ទូទាំងប្រទេស

បានចំនួន ១២,៧៩៦នាក់ និងផ្តល់ឧបករណ៍សម្រាប់បើកវគ្គបណ្តុះបណ្តាលដល់សាខាទាំង២៤ ដើម្បីផ្សព្វផ្សាយ និងផ្តល់វគ្គបណ្តុះបណ្តាលបន្តដល់សហគមន៍។

- ផ្តល់សេវាកម្មបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋមបង់ថ្លៃ ជូនដល់ក្រុមហ៊ុនឯកជន អង្គការមិនមែនរដ្ឋាភិបាលចំនួន ២,១៦៤នាក់ រកចំណូលបាន ៦៦,៦១៨ដុល្លារ ចូលក្នុងគណនីរបស់ កក្រក។

## III- **ទិសយុទ្ធសាស្ត្រទី៣ : ការលើកកម្ពស់គោលការណ៍គ្រឹះ តម្លៃមនុស្សធម៌ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងវប្បធម៌អហិង្សា (វិស័យស្នូលទី៣: ការលើកកម្ពស់គោលការណ៍គ្រឹះ និង តម្លៃមនុស្សធម៌របស់ចលនា)**

### សកម្មភាពទី ១ : ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម (៨ ឧសភា)

- រយៈពេល៤ឆ្នាំនេះ ទិវា ៨ ឧសភា នៅតែបន្តស្ថិតនៅ ជាពិធីដ៏ធំមួយ សម្រាប់សមាគមជាតិ ទាំងថ្នាក់កណ្តាល និងសាខាទាំង ២៤ រាជធានី-ខេត្ត ក្នុងការលើកកម្ពស់ជំនឿទុកចិត្ត ក៏ដូចជាការលើកកម្ពស់វប្បធម៌ចែករំលែក ជាពិសេសការកៀរគររកមូលនិធិ ដើម្បីត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយពីមួយឆ្នាំទៅមួយឆ្នាំ ឲ្យមានប្រសិទ្ធភាព។

មួយអាណត្តិទី៥ នេះ ចំនួនសប្បុរសជន និងថវិកាឧបត្ថម្ភគាំទ្រដល់ទិវា ៨ ឧសភា កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់សាខា ដែលទាំងនេះជាការឆ្លុះបញ្ចាំងឲ្យឃើញ ពីការរីកដុះដាលនៃកម្លាំងមនុស្សធម៌ ការជឿទុកចិត្តកាន់តែខ្លាំងឡើង ចំពោះកាកបាទក្រហមកម្ពុជា ដែលមាន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជាប្រធាន និងមាន **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីនៃអង្គពិធីរៀងរាល់ឆ្នាំ។

ដោយសារ ការលះបង់ទាំងទឹកចិត្ត និងមនោសញ្ចេតនា ផ្សារភ្ជាប់ជាមួយសុខទុក្ខ ការលំបាក របស់ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ដោយមិនប្រកាន់ភេទ ជំនឿសាសនា និងនិន្នាការនយោបាយ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា បានទទួលនូវការប្រោសប្រទានពី **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** នូវគោរមងារដ៏វិសេសថ្លៃថ្លា ជា**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ក្នុងឱកាសទិវា ៨ ឧសភា ឆ្នាំ២០១៣។

- ពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី **ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស ក៏នៅតែជាពិធីបុណ្យប្រចាំឆ្នាំ រៀបចំនៅថ្នាក់កណ្តាល និងសាខា ដោយនៅថ្នាក់កណ្តាលមានរៀបចំការចូលគាល់ថ្វាយព្រះពរ និងរាយការណ៍ពីសកម្មភាព មានកម្មវិធីពិសេស ៣ថ្ងៃ នៅទូរទស្សន៍ជាតិកម្ពុជា មានរៀបចំពិធីព្រះពុទ្ធសាសនាចម្រើនព្រះបរិត្ត រាប់បាត្រព្រះសង្ឃនៅទីស្នាក់ការកណ្តាល ថ្នាក់សាខាក៏រៀបចំពិធីព្រះពុទ្ធសាសនាទៅតាមលទ្ធភាព និងមានលិខិតថ្វាយព្រះពរទាំង ២៤ សាខា រាជធានី ខេត្ត ថ្វាយផ្ទាល់ដល់ព្រះអង្គ។

## សកម្មភាពទី២ ៖ លើកកម្ពស់ការផ្សព្វផ្សាយអំពីចលនា គោលការណ៍គ្រឹះ និងច្បាប់មនុស្សធម៌អន្តរជាតិ

បានបញ្ជ្រាប ក្នុងការប្រារព្ធទិវា ៨ ឧសភា កម្មវិធីបណ្តុះបណ្តាលយុវជន អ្នកស្ម័គ្រចិត្ត វិជ្ជាសង្គ្រោះបឋម ពេលចែកអំណោយទាំងនៅថ្នាក់កណ្តាល និងថ្នាក់សាខា។ ដើម្បីគុណភាពនៃការងារនេះ ថ្នាក់កណ្តាលបានបំពេញតួនាទីដូចខាងក្រោម ៖

- ការផ្សព្វផ្សាយអំពីកាកបាទក្រហម និងច្បាប់មនុស្សធម៌អន្តរជាតិ ដល់ មន្ត្រី យុវជន និង អ្នកស្ម័គ្រចិត្ត កក្រក ក្រសួង មន្ទីរ

កងកម្លាំងប្រដាប់អាវុធ មានការកើនឡើង ជាងអាណត្តិទី៤ គឺកើនពី ៤,០១៥ នាក់ ដល់១០,១១៩ នាក់ និងពី ៤៩ វគ្គ ឡើងដល់ ១៣៥ វគ្គ។

- រៀងរាល់ឆ្នាំ បានរៀបចំវេទិកាយុវជនកាកបាទក្រហម ដើម្បីអបអរទិវា ៨ ឧសភា នៅស្ទូឌីយោទូរទស្សន៍ជាតិកម្ពុជា មានយុវជនចូលរួមចំនួន ១៦៨នាក់ មកពីសាកលវិទ្យាល័យផ្សេងៗពីគ្នា។
- មានស្ថានីយ៍ទូរទស្សន៍ចំនួន ៨ និងទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ ចូលរួមចំណែកយ៉ាងសកម្ម ផ្សព្វផ្សាយអំពី កក្រក។ មានអ្នកយកព័ត៌មានពីស្ថានីយ៍ចំនួន ៣៤នាក់ បានក្លាយជា ភ្នាក់ងារផ្សព្វផ្សាយរបស់ កក្រក រួមជាមួយអ្នកនាំពាក្យប្រចាំសាខានីមួយៗ។ ទន្ទឹមនឹងនេះ បានបង្កើតបណ្តាញផ្សព្វផ្សាយផ្ទាល់តាមគេហទំព័រ និងបណ្តាញសង្គមហ្វេសប៊ុករបស់ កក្រក ចាប់ពីឆ្នាំ២០១៣ មក។
- ការងារស្តារទំនាក់ទំនងគ្រួសារក្នុងអាណត្តិទី៥ នេះ បានបញ្ជូនសារឆ្លើយឆ្លង កក្រក ចំនួន ៤៤,៣៧៥ច្បាប់ ជាសារឆ្លើយឆ្លងរវាងអ្នកទោសពន្ធនាគារ និងក្រុមគ្រួសារក្នុងស្រុក និង ៣៦៨ ច្បាប់ រវាងប្រជាពលរដ្ឋខ្មែរ ដែលជាប់ពន្ធនាគារនៅប្រទេសថៃ និងម៉ាឡេស៊ី។
- ការងារសុវត្ថិភាពសហគមន៍ អនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹង និងអប់រំអំពីមីន កាកសំណល់ពីសង្គ្រាម និងផ្តល់ប្រាក់កម្ចីខ្នាតតូចពុំមានការប្រាក់ រួមទាំងការផ្តល់ជំនួយមនុស្សធម៌សង្គ្រោះបន្ទាន់ដល់គ្រួសាររងគ្រោះ និងងាយរងគ្រោះដោយសារគ្រាប់មីន។ សកម្មភាពនេះ អនុវត្តនៅខេត្តគោលដៅចំនួន ៦ ទទួលបានលទ្ធផលសំខាន់ៗ មាន ៖

– ផ្ដល់ការអប់រំអំពីគ្រាប់មីន ប្រាក់កម្ចីខ្នាតតូច និងសុវត្ថិភាពសហគមន៍ ដល់ប្រជាពលរដ្ឋ ចំនួន ១៧២,០០០ នាក់ និងអ្នកស្ម័គ្រចិត្តចំនួន ១,៥០០ នាក់។

– ផ្ដល់ប្រាក់កម្ចីខ្នាតតូចជូនគ្រួសាររងគ្រោះ និងងាយរងគ្រោះដែលក្រីក្រ ចំនួន ១,៨៦២ គ្រួសារ ក្នុងនោះមានគ្រួសារចំនួន១,៤៨៩ មានជីវភាពប្រសើរឡើងជាងមុនហើយ។

## IV- **ទិសយុទ្ធសាស្ត្រទី៤**: **ពង្រឹងការគោរពកិត្តិនាមកាកបាទក្រហមកម្ពុជា ជាសមាគមជាតិមានដំណើរការល្អ (វិស័យស្នូលទី៤: ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន)**

### សកម្មភាពទី១ : ការអភិបាល និងការគ្រប់គ្រង

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនៅក្នុងយុទ្ធសាស្ត្រ ២០១១-២០២០ កក្រក ទាំងថ្នាក់កណ្ដាល និងថ្នាក់សាខា សម្រេចបានការងារទៅតាមកញ្ចប់ការងារអភិវឌ្ឍស្ថាប័ន គួរឲ្យកត់សំគាល់ដូចតទៅ ៖

- ទាំងថ្នាក់កណ្ដាល និងសាខាទាំង ២៤ បានដាក់ចេញនូវសេចក្ដីសម្រេច ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ កក្រក ចែងអំពីការបែងចែកជាពិសេស ក្រុមការងារទ្រទ្រង់សកម្មភាព យុវជន និងអ្នកស្ម័គ្រចិត្ត ដឹកនាំដោយ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធាន** ផ្ទាល់ ក្រុមប្រឹក្សាពិសេស ដឹកនាំដោយ **សម្ដេចចៅហ្វាវាំង** និងក្រុមការងារឯទៀត បានចូលរួមដឹកនាំ ដោយឥស្សរជនជាន់ខ្ពស់ នៅក្នុងជួរគណៈកម្មាធិការកណ្ដាល។
- បានបោះពុម្ពសៀវភៅកម្រងច្បាប់ ឲ្យត្រូវតាមការអនុម័តនៃអង្គមហាសន្និបាតអាណត្តិទី ៥។

**សកម្មភាពទី២ : ការអភិវឌ្ឍសាខា អនុសាខា**

- សាខាចំនួន៨ មានអគារសាខាថ្មី
- សាខាទាំង២៤ រាជធានី ខេត្ត បានប្រារព្ធសន្និបាតសាខាអាណត្តិទី៤ មានគណៈកិត្តិយសថ្មី មានគណៈកម្មាធិការសាខាថ្មី
- សាខាចំនួន ១៩ មានអគារអនុសាខាជាកម្មសិទ្ធិរបស់ កក្រក ចំនួន ៨១អនុសាខា លើចំនួន ស្រុកទូទាំងប្រទេស ១៩៤ស្រុក។
- ក្នុងអាណត្តិទី៣ មានសាខា១៩ បានចាត់តាំងគណៈកិត្តិយស និងគណៈកម្មាធិការអនុសាខា បាន ១៨០អនុសាខា។ ចាត់តាំងក្រុម កក្រក បានចំនួន ១,២៧៥ក្រុម លើចំនួនឃុំ-សង្កាត់ ចំនួន ១,៦២៩ រីឯអាណត្តិទី៤នេះ ទើបតែមានសាខា ៤ បានចាត់តាំងគណៈកិត្តិយស និងគណៈកម្មាធិការអនុសាខារួចហើយ និងមានសាខាដែលបានចាត់តាំងខ្លះនៅខ្លះ ព្រោះទើបតែរៀបចំសន្និបាតសាខារួច។
- តាមរយៈការវាយតម្លៃ លក្ខណៈវិនិច្ឆ័យនៃសាខាមានដំណើរការល្អ ក្នុងឆ្នាំ២០១៤ នេះ ជាលទ្ធផលបណ្តោះអាសន្ន ក្នុងចំណោមសាខាទាំង២៤ ដែលបានបំពេញតារាងវាយតម្លៃ មានសាខា១៦ ជាប់ក្នុងចំណាត់ ថ្នាក់ "ក" សាខា៨ ជាប់ក្នុងចំណាត់ថ្នាក់ "ខ" មិនមានសាខាក្នុងចំណាត់ថ្នាក់ "គ" ទៀតទេ។ ប្រៀបធៀបនឹងការវាយតម្លៃនេះ ក្នុងឆ្នាំ២០១០ សាខាក្នុងចំណាត់ថ្នាក់ "ក" មានតែ១០ ប៉ុណ្ណោះ ក្នុងចំណាត់ថ្នាក់ "ខ" មាន១៣ ក្នុងចំណាត់ថ្នាក់ "គ" មាន ១។

## សកម្មភាពទី៣ : ការអភិវឌ្ឍយុវជន និងអ្នកស្ម័គ្រចិត្ត កក្រក

យុវជន និងអ្នកស្ម័គ្រចិត្ត ជាកម្លាំងចលករមិនអាចខ្វះបានរបស់ចលនា។ រយៈពេល៤ឆ្នាំ នៃ អាណត្តិទី៥នេះ ក្រោមការដឹកនាំដ៏ឧត្តុង្គឧត្តម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ការរៀបចំចាត់ចែង គ្រប់គ្រងការអភិវឌ្ឍយុវជន និងអ្នកស្ម័គ្រចិត្ត សម្រេចបានលទ្ធផលគួរឲ្យកត់សំគាល់ដូចតទៅ ៖

### ១- ការអភិវឌ្ឍយុជន កក្រក

- សមាជិកយុវជនសារុប ២៩,០៩៩នាក់ (ស្រី១៥,៧៨៩នាក់) ដែលកាលពីអាណត្តិទី៤ មាន ១៤,៦៧៦ នាក់ (ស្រី ៦៦៧៥ នាក់)។ ទីប្រឹក្សាយុវជន សរុប ៩៧០ នាក់ (ស្រី ២៦៤ នាក់) នៅសាលាបឋមសិក្សាចំនួន១១ អនុវិទ្យាល័យ ៧១ វិទ្យាល័យ ៣៣២ នៅសាលាគរុកោសល្យ និងវិក្រឹត្យការចំនួន ១ សាកលវិទ្យាល័យចំនួន ២៧ ( នៅរាជធានីភ្នំពេញចំនួន១៨ នៅតាមខេត្ត ចំនួន ៩) ពីអាណត្តិទី៤ មានតែ ១៣ សាកលវិទ្យាល័យប៉ុណ្ណោះ។
- ឆ្នាំ២០១៤ នេះ កក្រក បានធ្វើជាប្រធាននៃបណ្តាញយុវជនកាកបាទក្រហម អឌ្ឍចន្ទក្រហម នៃភូមិភាគអាស៊ីអាគ្នេយ៍ និងជាអនុប្រធាននៃបណ្តាញយុវជនតំបន់អាស៊ីប៉ាស៊ីហ្វិច។

### ២-ការអភិវឌ្ឍអ្នកស្ម័គ្រចិត្ត កក្រក

- ក្រៅពីអ្នកស្ម័គ្រចិត្តនៅក្នុងជួរគណៈអភិបាល និងនៅក្នុងការិយាល័យ ចំនួនអ្នកស្ម័គ្រចិត្តនៅ តាមភូមិសារុប ២០,៤៥៦ នាក់ បានទទួលការបណ្តុះបណ្តាលការយល់ដឹងអំពីចលនា គោលការណ៍គ្រឹះ និងច្បាប់មនុស្សធម៌អន្តរជាតិ វិជ្ជាសង្គ្រោះបឋម និងជំនាញការងារជាក់លាក់ ពាក់ព័ន្ធនឹងការអប់រំសុខភាពស្រ្តី និង

កុមារ ទឹកស្អាត និងអនាម័យ ផ្សព្វផ្សាយអំពីគ្រោះថ្នាក់ដោយសារមីន គ្រោះថ្នាក់ចរាចរណ៍ ការគ្រប់គ្រងគ្រោះមហន្តរាយ។ល។

កម្លាំងអ្នកស្ម័គ្រចិត្ត និងយុវជន កក្រក នៅទូទាំងប្រទេស បានរួមចំណែកយ៉ាងសកម្ម ក្នុងការដោះស្រាយផលវិបាកទាំងឡាយ ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមជាច្រើន តាមរយៈការឆ្លើយតបគ្រោះមហន្តរាយ និងការអនុវត្តគម្រោងកម្មវិធីនានា នៅតាមសហគមន៍។

## ទិសដៅការងារ អាណត្តិទី ៦

អាណត្តិទី៦ ជាដំណាក់កាលចុងក្រោយ នៃការអនុវត្តយុទ្ធសាស្រ្ត ១០ឆ្នាំ ២០១១-២០២០ ដែល បានចែងច្បាស់នូវលទ្ធផលរំពឹងទុក និងសកម្មភាពចម្បងៗ នៃវិស័យស្នូលនីមួយៗ។ ដូចនេះ ទិសដៅសំខាន់ៗ នៃវិស័យស្នូលនីមួយៗ មានដូចតទៅ ៖

### វិស័យស្នូល ទី១ : ការគ្រប់គ្រងគ្រោះមហន្តរាយ

- ពង្រឹងសមត្ថភាពត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់សាខា ឲ្យទៅតាមស្តង់ដារឯកភាពគ្នាទូទាំងប្រទេស។
- បន្តបង្កើនភាពធន់មាំរបស់គ្រួសារនីមួយៗ សហគមន៍នីមួយៗ ដើម្បីត្រៀមជាស្រេចក្នុងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដោយបញ្ជ្រាបការយល់ដឹងបន្ថែមទៀត អំពីបម្រែបម្រួលអាកាសធាតុ តាមរយៈការពង្រីក ពង្រឹងបណ្តាញអ្នកស្ម័គ្រចិត្ត និងយុវជន កក្រក។

- ពង្រឹងសមត្ថភាព ក្នុងការងារសុវត្ថិភាពចរាចរណ៍ ធ្វើឲ្យមន្ត្រី-បុគ្គលិក អ្នកស្ម័គ្រចិត្ត យុវជន សមាជិក សមាជិកា កក្រក ម្នាក់ៗក្លាយជាអ្នកអប់រំអំពីសុវត្ថិភាព ចរាចរណ៍មួយរូប តាមទិសស្លោក "**ថ្ងៃនេះ ថ្ងៃស្អែក កុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍។** បញ្ជ្រាបការងារសុវត្ថិភាពចរាចរណ៍ ទៅក្នុង គ្រប់គម្រោង កម្មវិធី ឬសកម្មភាពមនុស្សធម៌ទាំងអស់។
- បន្តពង្រឹង ពង្រីកប្រាក់កម្ចីខ្នាតតូចពុំមានការប្រាក់ ជាមួយជនងាយរងគ្រោះ ជាពិសេស ដោយថវិកាវិលម៉េត ឲ្យកាន់តែមានប្រសិទ្ធភាព ជាងនេះទៀត។
- បន្តពង្រឹងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេស គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទាំងនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដើម្បីការត្រៀមបង្ការ និងឆ្លើយតបគ្រោះមហន្តរាយ បានប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព។
- បញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងគ្រប់សកម្មភាពការងារ។

## វិស័យស្នូល ទី២ : សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍

- បញ្ជ្រាបការងារតស៊ូរជនឆ្នើមថ្នាក់ជាតិ ដោយបង្កើតឯកសារគំរូសម្រាប់ ប្រើប្រាស់ឯកភាពគ្នាទូទាំងប្រទេស។
- បន្តប្រើប្រាស់ថវិកាវិលម៉េត សាងសង់អណ្តូងទឹកស្អាត ឬស្រះទឹកជូនសហគមន៍ ដែលមានតម្រូវការពិតប្រាកដ ជាមួយនឹងការអប់រំសុខភាព អនាម័យផងដែរ។
- បន្តពង្រឹង និងពង្រីក ការងារអភិវឌ្ឍន៍សុខភាពសហគមន៍មូលដ្ឋាន តាមរយៈបណ្តាញ អ្នកស្ម័គ្រចិត្ត និងយុវជន កក្រក ដែលអាចចាត់ទុកជាភ្នាក់ងារផ្លាស់ប្តូរឥរិយាបថ របស់សហគមន៍។

- បន្តពង្រីក ពង្រឹងការផ្សព្វផ្សាយ និងបណ្តុះបណ្តាលជំនាញវិជ្ជាសង្គ្រោះបឋម ឈានទៅដល់សមាជិកក្រុមគ្រួសារនីមួយៗ ស្ថាប័ននីមួយៗ សហគមន៍ និងរោងចក្រ សហគ្រាសនីមួយៗផងដែរ ដោយសហការជាមួយក្រសួងការងារ និងស្ថាប័នពាក់ព័ន្ធ។

**វិស័យស្នូល ទី៣ : ការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌**

- លើកកម្ពស់ការផ្សព្វផ្សាយឲ្យបានទូលំទូលាយថែមទៀត។
- ពង្រឹងការកសាងសមត្ថភាពការងារទំនាក់ទំនង ដើម្បីលើកកម្ពស់កិត្តិនាមកាកបាទក្រហមកម្ពុជា និងការចូលទៅបំពេញការងារមនុស្សធម៌ ប្រកបដោយសុវត្ថិភាព។
- កសាង និងអនុវត្តផែនការអភិវឌ្ឍ (២០១៥-២០២០) ស្តីពីការងារទំនាក់ទំនង។
- ធ្វើការអង្កេត ទស្សនៈយល់ដឹងរបស់សាធារណៈជន ចំពោះកាកបាទក្រហមកម្ពុជា ជាលើកទី២។
- កសាង និងអនុវត្តផែនការអភិវឌ្ឍ (២០១៥-២០២០) ស្តីពីការងារស្តារទំនាក់ទំនងគ្រួសារ។
- បន្តអនុវត្តផែនការយុទ្ធសាស្រ្ត៤ឆ្នាំ ស្តីពីសុវត្ថិភាពសហគមន៍។

**វិស័យស្នូល ទី៤ : ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន**

- ពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តយុទ្ធសាស្រ្ត (២០១១-២០២០) រយៈពេល៥ឆ្នាំ (គិត ត្រឹមឆ្នាំ២០១៥) និងកសាងផែនការអភិវឌ្ឍអាណត្តិទី ៦។
- បន្តពង្រឹង និងពង្រីកការអភិវឌ្ឍស្ថាប័ន អភិវឌ្ឍសាខា តាមទិសវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធ្វើសកម្មភាពអន្តរវិស័យស្នូល ជួយជនងាយរងគ្រោះបំផុត ទាន់ពេលវេលា។ ដូចនេះ គ្រប់ស្រុក

ទាំងអស់ នៅទូទាំងប្រទេស មានអគារអនុសាខា កក្រក មានដំណើរការល្អ មានក្រុម កក្រក តាមឃុំ មានអ្នកស្ម័គ្រចិត្តគ្រប់ភូមិ។

- ពង្រីក និងពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធការងារ និងការបំពេញបង្គ្រប់ឲ្យគ្នា ជួយគាំទ្រគ្នាទៅវិញ ទៅមក រវាងថ្នាក់កណ្តាល និងសាខា រវាងគណៈអភិបាល និងក្រុមប្រតិបត្តិ នៅថ្នាក់សាខា អនុសាខា។
- បន្តលើកកម្ពស់អភិបាលកិច្ចល្អ ការគ្រប់គ្រងមានតម្លាភាព នៅថ្នាក់សាខាថែមទៀត។
- បន្តអភិវឌ្ឍឲ្យបានខ្លាំងក្លាថែមទៀត កម្លាំងយុវជន និងអ្នកស្ម័គ្រចិត្ត កក្រក ឲ្យទៅជាកម្លាំងចលករពិតប្រាកដ របស់សមាគមជាតិ និងជាក្តីរំពឹង របស់ប្រជាពលរដ្ឋងាយរងគ្រោះ និងរងគ្រោះ។
- កសាងយុទ្ធសាស្ត្រ (២០២០-២០៣០)។
- រៀបចំមហាសន្និបាត កក្រក អាណត្តិទី៧ សន្និបាតយុវជនលើកទី៤ សន្និបាតសាខា កក្រក អាណត្តិទី៥ និងសន្និបាតអនុសាខា កក្រក អាណត្តិទី ១។

## សេចក្តីសន្និដ្ឋាន

សមិទ្ធផល និងជោគជ័យ ដែលសម្រេចបានទាំងនេះ គឺដោយសារមានព្រះរាជវីរៈគំរូ **ព្រះវររាជ បិតាជាតិខ្មែរ ព្រះបរមរតនៈកោដ្ឋ** ជាព្រះស្ថាបនិក កក្រក **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និងសម្តេចព្រះមហាក្សត្រី **ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស ដែលបានយកព្រះរាជហឫទ័យទុកដាក់ជាមួយ កក្រក តាមរយៈព្រះរាជូបត្ថម្ភ ព្រះរាជទ្រព្យ រៀងរាល់ខែ រាល់ត្រីមាស រួមជាមួយនឹងព្រះរាជទានក្នុងឱកាសផ្សេងៗទៀត ជាពិសេស ពេលមានគ្រោះមហន្តរាយកើតឡើង

និងទិវា ៨ ឧសភា ព្រមជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** អញ្ជើញជាអធិបតីក្នុងទិវា ៨ ឧសភា រៀងរាល់ឆ្នាំ ដោយការផ្តល់នូវជំនឿទុកចិត្ត និងលើកទឹកចិត្ត ផ្តល់ភាពកក់ក្តៅចំពោះ កក្រក ឲ្យបំពេញបេសកកម្ម ជាជំនួយការឲ្យរាជរដ្ឋាភិបាលដោយរលូន និងមានប្រសិទ្ធភាព។ ប្រការមិនអាចខ្វះបាន គឺដោយសារ មានការគាំទ្រយ៉ាងពេញទំហឹងពី រាជរដ្ឋាភិបាល ស្ថាប័នជាតិ ស្ថាប័នសាធារណៈ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ គ្រប់ប្រភេទ សហព័ន្ធអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ កត្តាកំណត់ និងសំខាន់បំផុតនោះ គឺការដឹកនាំប្រកបដោយ ភាពឈ្លាសវៃរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ដែលបានលះបង់អស់ កម្លាំង កាយចិត្ត និងពេលវេលា យកទុក្ខលំបាករបស់ជនងាយរងគ្រោះ ជាអាទិភាព កៀរគរកម្លាំងសរុបទាំងថ្នាក់កណ្តាល និងសាខា ឯកភាពគ្នា ដឹកនាំសមាគមជាតិទាំងមូល **ធ្វើឲ្យបានកាន់តែច្រើនជាងមុន ធ្វើឲ្យបានកាន់តែល្អជាងមុន ធ្វើឲ្យបានកាន់តែស៊ីជម្រៅ និងទៅឲ្យបានកាន់តែឆ្ងាយជាងមុន។** ការងារមនុស្សធម៌ ជាការងារមួយដ៏ធំធេង ធ្ងន់ធ្ងរ តែឧត្តុង្គឧត្តម មិនអាចមានតួអង្គណាម្នាក់ ស្ថាប័នណាមួយ ឬប្រទេសណាមួយ សម្រេចតែឯកឯងបានឡើយ។ ដូចនេះ ចាំបាច់ត្រូវមានការចូលរួមចំណែកឧបត្ថម្ភគាំទ្រ ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ ដូចនេះហើយទើប " **កម្លាំងមនុស្សធម៌ និងវប្បធម៌ចែករំលែក** " នៅតែជាគោលការណ៍ដ៏សំខាន់មិនអាចខ្វះបាន។

សមិទ្ធផល និងជោគជ័យ ដែលសម្រេចបាននេះ បានផ្តល់នូវភាពកក់ក្តៅ ចំពោះអ្នកទទួលផល ហើយក៏បានលើកកម្ពស់ជំនឿទុកចិត្តពីគ្រប់

មជ្ឈដ្ឋាន អំពីអត្ថិភាព កក្រក សមាគមជាតិនាំមុខគេ ក្នុងវិស័យមនុស្សធម៌ នេះជាការលើកទឹកចិត្តយ៉ាងខ្លាំង ក្នុងការខិតខំប្រឹងប្រែងទ្វេដង ច្រើនទៀត ក្នុងស្មារតី ពង្រឹងមនោសញ្ចេតនាយើងទាំងអស់គ្នា ***ដើម្បីមនុស្សធម៌*** ដោយ ផ្តោតលើប្រធានបទថ្មី "***ខ្ញុំ និងកាកបាទក្រហម***" អះអាងថា បាននិងកំពុង ហើយនិងរួមកម្លាំងគ្នាជាធ្លុងមួយ ផ្តល់សេវាកម្មមនុស្សធម៌ ជួយដល់ជនងាយ រងគ្រោះ និងរងគ្រោះ បានទាន់ពេលវេលា និងមានប្រសិទ្ធភាពថែមទៀត។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ គ្រាន់តែជាសេចក្តី សង្ខេបប៉ុណ្ណោះ សេចក្តីព្រាង របាយការណ៍ពេញលេញបានចម្លងជូននៅក្នុង កញ្ចប់ឯកសាររួចហើយ សូម គណៈអធិបតី សមាជិក សមាជិកា នៃអង្គ មហាសន្និបាតអាណត្តិទី៦ មេត្តាជ្រាបទុកជាមូលដ្ឋានសម្រាប់ការពិភាក្សា ដើម្បីឈាន ទៅធ្វើការអនុម័ត។

***សូមអរគុណ!***